**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ០២១៨ ព.ណ.អ.ន.ស

ថ្ងៃ ចន្ទ ៤ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែកុម្ភៈ ឆ្នាំ២០២១ នឹងត្រូវលក់ ៣.៥៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.២១០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែកុម្ភៈ ឆ្នាំ២០២១** នឹងចុះមក ៣.៤០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.០៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៣៧៣៩ ដុល្លារ | ០,៣៨០៥ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៨៤៧ ដុល្លារ | ០,០៧៤២ ដុល្លារ |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,១០១៣ ដុល្លារ | ០,០៣៤២ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៧៥៩ ដុល្លារ | ០,០៦៨៥ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៨៣៤៥ ដុល្លារ | ០,៧៥៣២ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៣៩២ រៀល | ៣.០៦២ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៨៣ ដុល្លារ | ០,៧៥ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៤០០ រៀល | ៣.០៥០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដែលស្មើនឹង៤.០៦៥រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៨ មករា ២០២១ | ៥៨,២៣ | ៦០,០៣ |
| ១៩ មករា ២០២១ | ៥៩,០០ | ៦០,៧២ |
| ២០ មករា ២០២១ | ៥៩,៥៦ | ៦១,៦៤ |
| ២១ មករា ២០២១ | ៥៩,៣៤ | ៦០,៦៥ |
| ២២ មករា ២០២១ | ៥៩,០៧ | ៥៩,៨៣ |
| ២៥ មករា ២០២១ | ៥៩,៦១ | ៦០,០៥ |
| ២៦ មករា ២០២១ | ៥៩,៥៦ | ៦០,២០ |
| ២៧ មករា ២០២១ | ៦០,៥០ | ៦០,៩៨ |
| ២៨ មករា ២០២១ | ៥៩,៦៥ | ៦០,៥៤ |
| ២៩ មករា ២០២១ | ៥៩,៥៦ | ៦០,៤២ |
| **មធ្យមភាគ ១០ថ្ងៃ** | **៥៩,៤៥១០** | **៦០,៥០៦០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៣៧៣៩** | **០,៣៨០៥** |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ ០១ ខែកុម្ភៈ ឆ្នាំ២០២១




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ប្រតិបត្តិតាមការចាំបាច់។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម